**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពីឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ ភូមិអូរតាប៉ាង**
**ឃុំអូរចំណារ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ**
**ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលដំណឹងថា មានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ ក្រឡាប់រថយន្តដឹកកម្មករ កាលពីវេលាម៉ោង៦និង៣០នាទីព្រឹក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្ថិតនៅចន្លោះគីឡូម៉ែត្រលេខ១៩៣ និង១៩៤ ភូមិអូរតាប៉ាង ឃុំអូរចំណារ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលបានបណ្តាលឱ្យកម្មកររងរបួសធ្ងន់ស្រាលចំនួន២៥នាក់ ក្នុងនោះរបួសធ្ងន់ចំនួន ០៣នាក់ និងរបួសស្រាលចំនួន២២នាក់។ អ្នករងរបួសទាំងនេះ បានទទួលការជួយសង្គ្រោះពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីបេឡាជាតិរបបសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយយកចិត្តទុកដាក់បំផុត។ គិតត្រឹមម៉ោង ១០និង០០ នាទីព្រឹក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ នេះ មានកម្មករនិយោជិតចំនួន១៨នាក់ បាននិងកំពុងសម្រាកព្យាបាលនៅគ្លីនិក ផូជាន់នី ចំនួន០៥នាក់ សម្រាកព្យាបាលនៅគ្លីនិកវណ្ណៈ វាលរេញ និងចំនួន ០២នាក់ សម្រាកព្យាបាលនៅមន្ទីរពេទ្យតេសេ ខេត្តព្រះសីហនុ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមចូលរួមរំលែកនូវសេចក្តីសោកស្តាយ និងអាណិតស្រឡាញ់ជាទីបំផុតជាមួយក្រុមគ្រួសារ និងញាតិមិត្តទាំងអស់របស់ជនរងគ្រោះ ហើយសូមជូនពរដល់អ្នករងរបួសទាំងអស់ឆាប់បានជាសះស្បើយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តជួយដោះស្រាយទុក្ខលំបាករបស់បងប្អូនកម្មការិនី និងក្រុមគ្រួសារទៅតាមគោលរបបសន្តិសុខសង្គមរបស់បេឡាជាតិរបបសន្តិសុខសង្គម។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៦

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩